**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៩៩៤ មស.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបើកផ្តល់ប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យា

យោងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងសារាចរលេខ០១សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ព្រមទាំងដើម្បីធានាការបើកផ្តល់ប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាឱ្យបានទាន់ពេលវេលា ក្រសួងមុខងារសាធារណៈ សូមជម្រាបដល់គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ដែលប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាដូចខាងក្រោម៖

**ក. ថ្នាក់ក្រសួង ស្ថាប័ន**

១. ក្រសួង ស្ថាប័ន ត្រូវបញ្ចូលឬធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីជាប់កិច្ចសន្យាក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈនិងបង្កើតតារាងទូទាត់ប្រាក់កម្រៃប្រចាំខែយ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១នៃខែនីមួយៗ។

២. ក្រសួងមុខងារសាធារណៈ ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យាក្នុងសប្តាហ៍ទី២នៃខែនីមួយៗ។ ផុតរយៈពេលកំណត់នេះ ប្រសិនពុំមានការជំទាស់ ឬការតម្រូវឱ្យមានការកែប្រែណាមួយដោយក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័នសាមីត្រូវអនុម័តតារាងទូទាត់ប្រាក់កម្រៃប្រចាំខែជាការបញ្ចប់ការកែប្រែនិងរៀបចំអាណត្តិបើកប្រាក់ដោយផ្អែកលើមូលដ្ឋានទិន្នន័យនៅក្នុងតារាងនេះក្នុងសប្តាហ៍ទី៣នៃខែនីមួយៗ។

៣. ជាបន្ត ក្រសួង ស្ថាប័ន ត្រូវអនុវត្តនីតិវិធីបើកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាអនុលោមតាមស្មារតីនៃសារាចរលេខ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំសំណើសុំបើកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាទៅធនាគារពាណិជ្ជដែលជាដៃគូរ ដើម្បីរៀបចំបញ្ចូលប្រាក់កម្រៃទៅក្នុងគណនីមន្ត្រីជាប់កិច្ចសន្យាតាមតារាងទូទាត់ប្រាក់កម្រៃប្រចាំខែដែលអនុម័តរួចនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យានិងតាមចំនួនទឹកប្រាក់ដែលបានកំណត់ក្នុងអាណត្តិបើកប្រាក់។

**ខ. ថ្នាក់រាជធានី ខេត្ត**

១. សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវផ្តល់ឯកសារតម្រូវពាក់ព័ន្ធនឹងមន្ត្រីជាប់កិច្ចសន្យាដែលបំពេញការងារនៅអង្គភាពរបស់ខ្លួនដល់មន្ទីរមុខងារសាធារណៈរាជធានី



ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ខេត្ត យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១នៃខែនីមួយៗ ដើម្បីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត បញ្ចូលឬធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីជាប់កិច្ចសន្យាក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ។

២. មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវបង្កើតតារាងទូទាត់ប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យានៃសាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្តក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យានិងពិនិត្យអនុម័តតារាងនេះជាការបញ្ចប់ការកែប្រែ។

៣. មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវផ្តល់តារាងទូទាត់ប្រាក់កម្រៃអនុម័តរួចជូនសាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ក្នុងសប្តាហ៍ទី២នៃខែនីមួយៗដើម្បីរៀបចំធ្វើអាណត្តិបើកប្រាក់ ។

៤. ជាបន្ត សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវអនុវត្តនីតិវិធីបើកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាអនុលោមតាមស្មារតីនៃសារាចរលេខ០១សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវរៀបចំសំណើសុំបើកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាទៅធនាគារពាណិជ្ជជាដៃគូរ ដើម្បីរៀបចំបញ្ចូលប្រាក់កម្រៃទៅក្នុងគណនីមន្ត្រីជាប់កិច្ចសន្យាតាមតារាងទូទាត់ប្រាក់កម្រៃប្រចាំខែដែលបានអនុម័តរួចនៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យានិងតាមចំនួនទឹកប្រាក់ដែលបានកំណត់ក្នុងអាណត្តិបើកប្រាក់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវទទួលខុសត្រូវនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ